សហព័ន្ធឧស្សាហកម្មយានយន្តកម្ពុជា
CAMBODIA AUTOMOTIVE INDUSTRY FEDERATION
ស.ឧ.យ.ក
CAIF

**សិក្ខាសាលា៖**

# “សិទ្ធិផ្តាច់មុខ និង បញ្ហាប្រឈម ក្នុងឧស្សាហកម្មយានយន្តកម្ពុជា”

**ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០២១**

# សេចក្តីណែនាំពីសមាគម

- *សហព័ន្ធឧស្សាហកម្មយានយន្តកម្ពុជា គឺជាសមាគមដែលតំណាងអោយក្រុមហ៊ុនទទួលបានសិទ្ធិនាំចូល និងចែកចាយរថយន្តថ្មីក្នុងព្រះរាជាណាចក្រកម្ពុជា ហើយបច្ចុប្បន្នមានម៉ាករថយន្តជាង ២០ ម៉ាក ជាសមាជិក និងកំពុងកើនឡើងជាបន្តបន្ទាប់។*

- *គោលបំណងសំខាន់របស់សមាគម គឺជំរុញការអភិវឌ្ឍវិស័យឧស្សាហកម្មយានយន្តក្នុងប្រទេសកម្ពុជា ស្ថិតក្នុងលក្ខណៈត្រឹមត្រូវ ស្មើភាព តម្លាភាព និងបង្កើតអោយមានតុល្យភាពរវាងតំរូវការ ក្រុមហ៊ុនដែលទទួលបានសិទ្ធិនាំចូល និងចែកចាយរថយន្ត អ្នកប្រើប្រាស់ និង និយ័តករ។*



Dr. Tan Monivann
*ប្រធានសមាគម*

# សេចក្ដីណែនាំពីសមាគម

## ក្រុមប្រឹក្សាភិបាល

## Board of Directors



**Peter Brongers**
ប្រធាន



**Ngorn Saing**
អនុប្រធាន



**Ryoji Fujita**
អនុប្រធាន



**James Zemke**
លេខាធិការ



**Hy Ramy**
ហិរញ្ញិក



**Seng Voeung**
សមាជិក



**Roberto da Silva**
សមាជិក

# សេចក្តីណែនាំពីសមាគម

សមាជិកសហព័ន្ធឧស្សាហកម្មយានយន្តកម្ពុជា ប្តេជ្ញាចិត្តក្នុងការអភិវឌ្ឍវិស័យឧស្សាហកម្មយានយន្តក្នុងផែនការរយៈពេលវែង៖

- ទំហំវិនិយោគ គិតជាទឹកប្រាក់លើសពី ១០០ លានដុល្លារ

សមាជិកសហព័ន្ធឧស្សាហកម្មយានយន្តកម្ពុជា ចូលរួមអភិវឌ្ឍធនធានមនុស្ស បង្កើនសមត្ថភាព និង ជំនាញក្នុងប្រទេសកម្ពុជា៖

- បានបង្កើតការងារជាង ៥ ពាន់ កន្លែង
- បានបញ្ជូនបុគ្គលិកទៅទទួលការបណ្តុះបណ្តាលនៅក្រៅប្រទេស និងពាំនាំនូវជំនាញបច្ចេកទេសត្រលប់មកវិញ
- បានអញ្ជើញគ្រូបច្ចេកទេសពីក្រៅប្រទេសមកបណ្តុះបណ្តាល បង្កើនសមត្ថភាព និងជំនាញបច្ចេកទេស។

សមាជិក CAIF

# សេចក្តីណែនាំពីសមាគម

សមាជិកសហព័ន្ធឧស្សាហកម្មយានយន្តកម្ពុជា៖

- បានវិនិយោគលើអគារតាំងបង្ហាញ និង សំភារៈបរិក្ខា
- នាំយកផលិតផល និងសេវាកម្មលក្ខណៈអន្តរជាតិផ្តល់ជូនអតិថិជន
- បង្កើតការងារ និងឱកាសសំរាប់ប្រជាពលរដ្ឋកម្ពុជា
- បណ្តុះបណ្តាល និងបង្កើនជំនាញដល់បុគ្គលិក
- បញ្ជូនបុគ្គលិកទៅហាត់ការនៅក្រៅប្រទេស
- បំពេញនូវរាល់កាតព្វកិច្ចពន្ធដែលតម្រូវ
- គោរពតាមបទបញ្ញត្តិ និងច្បាប់របស់ព្រះរាណាចក្រកម្ពុជា។

សាខាលក់រថយន្ត៖ ចំនួន ៣៣ ទីតាំង ទូទាំងប្រទេស

| ២៦ ទីតាំង | ៣ ទីតាំង | ២ ទីតាំង | ២ ទីតាំង |
|---|---|---|---|
| ភ្នំពេញ | សៀមរាប | បាត់ដំបង | កំពង់ចាម |



# សេចក្តីណែនាំពីសមាគម

## អគារលក់រថយន្ត























# សេចក្តីណែនាំពីសមាគម

## ផ្នែកសេវាកម្ម និង គ្រឿងបន្លាស់



# សេចក្តីណែនាំពីសមាគម

## រោងចក្រតំឡើងរថយន្ត

### Camko Motor Co.,Ltd

ម៉ាក: Hyundai

សម្ពោធ: ឆ្នាំ ២០១១

ទីតាំង: Koh Kong SEZ

ខេត្តកោះកុង




### Dae Han Auto (Cambodia)

ម៉ាក: SsangYong

សម្ពោធ: ឆ្នាំ ២០១៨

ទីតាំង: Bavet SEZ

ខេត្តស្វាយរៀង



### RMA Automotive Cambodia

ម៉ាក: Ford

សម្ពោធ: ដើមឆ្នាំ ២០២២

ទីតាំង: Krokor SEZ

ខេត្តពោធិ៍សាត់



# សេចក្តីណែនាំពីសមាគម

## រោងចក្រតំឡើងរថយន្ត

HGB Motors Assembly Co.,Ltd

ម៉ាក: ??

សម្ភាធ: ? ?

ទីតាំង: ប៉ោយប៉ែត

ខេត្តបន្ទាយមានជ័យ

**HGB Motors enters car assembly arena with $7M Poipet investment**



Workers of Japan's auto maker Fuji Heavy Industries assemble auto parts to the vehicle. HGB Motors Assembly Co Ltd is investing about $7 million in a car assembly plant in Poipet town, Banteay Meanchey province. AFP

# សេចក្តីណែនាំពីសមាគម

## ទិន្នន័យយានយន្តក្នុងឆ្នាំ ២០២០

| | | | |
|---|---|---|---|
| ទិន្នន័យនាំចូល | ៧៣ ៨១១ គ្រឿង | ទិន្នន័យចុះបញ្ជី | ៦៦ ២០៧ គ្រឿង |
| រថយន្តជជុះ | ៧៥% | រថយន្តថ្មី | ២៥% |






# បញ្ហាប្រឈមក្នុងឧស្សាហកម្មយានយន្ត



# បញ្ហាប្រឈមក្នុងឧស្សាហកម្មយានយន្ត

## សិទ្ធិផ្តាច់មុខ

**ការចុះបញ្ជី និង តម្កល់សិទ្ធិផ្តាច់មុខ៖**

តំរូវអោយចុះបញ្ជីតាមម៉ាក និងម៉ូដែល ដែលទទួលបានសិទ្ធិផ្តាច់មុខ

**លក្ខណ្ឌ និង វិសាលភាព៖**

គ្របដណ្តប់លើរថយន្តថ្មី ១០០% តែប៉ុណ្ណោះ ដែលរថយន្តមិនទាន់ដាក់លក់លើទីផ្សារជាលើកដំបូង

**លក្ខណៈសម្បត្តិរថយន្តថ្មី៖**

មិនត្រូវបានចុះបញ្ជី ផ្ទេរឈ្មោះ ដាក់លក់ ឬជួល ដោយអជ្ញាធរ ឬ ក្រុមហ៊ុនណាមួយ មុនពេលនាំចូលឡើយ

ត្រូវមានឆ្នាំផលិត ឬ ឆ្នាំម៉ូដែល ក្នុងឆ្នាំបច្ចុប្បន្ន ឬមួយឆ្នាំមុន ឬ មួយឆ្នាំក្រោយឆ្នាំបច្ចុប្បន្ន

# បញ្ហាប្រឈមក្នុងឧស្សាហកម្មយានយន្ត

## សិទ្ធិផ្តាច់មុខ

**ក្រសួងពាណិជ្ជកម្ម**

ប្រកាសលេខ ២២៨៧

២០ កក្កដា ២០២០



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម

លេខ ២២៨៧ ព.ណ.កសរ.

ថ្ងៃ ចន្ទ ១៥កើត ខែ អាសាឍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ២០២០

**ជម្រាបជូន**

- **លោកប្រធានសហព័ន្ធឧស្សាហកម្មយានយន្តកម្ពុជា (CAIF)**
- **លោកប្រធានសមាគមអ្នកលក់យានយន្តកម្ពុជា (CADA)**

**កម្មវត្ថុ ៖** ការកំណត់លក្ខណៈសម្បត្តិយានយន្តថ្មី ពាក់ព័ន្ធនឹងការកត់ត្រា និងតម្កល់លិខិតប្រគល់សិទ្ធិនាំចូលទំនិញពាក់ម៉ាកផ្តាច់មុខ។

**យោង ៖**
- ច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់
- សារាចរណែនាំលេខ ០៧ សរណន ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០១៥ ស្តីពីការទទួលស្គាល់សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាក
- ប្រកាសលេខ ១៨៦ ព.ណ កសប.ប្រក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៦ ស្តីពីនីតិវិធីសម្រាប់ការកត់ត្រា និងតម្កល់លិខិតប្រគល់សិទ្ធិនាំចូលទំនិញពាក់ម៉ាកផ្តាច់មុខ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាប **លោកប្រធាន** ថា ការតម្កល់លិខិតប្រគល់សិទ្ធិនាំចូលទំនិញពាក់ម៉ាកផ្តាច់មុខនៅក្រសួងពាណិជ្ជកម្ម មានលក្ខខណ្ឌ និងវិសាលភាព ដូចខាងក្រោម៖

- ការបញ្ជាក់អំពីសិទ្ធិផ្តាច់មុខលើម៉ាក និងការកត់ត្រា និងតម្កល់លិខិតប្រគល់សិទ្ធិផ្តាច់មុខ គ្របដណ្តប់តែលើទំនិញសុទ្ធនិងថ្មី ដែលមិនទាន់បានដាក់លក់ជាលើកដំបូងក្នុងទីផ្សារនៃព្រះរាជាណាចក្រកម្ពុជា។
- សិទ្ធិផ្តាច់មុខដែលទទួលបានពីការចុះបញ្ជី អាចផ្ទេរទៅឱ្យភាគីណាមួយបាន លុះត្រាតែមានការយល់ព្រមពីម្ចាស់ម៉ាក និងធ្វើការកត់ត្រា និងតម្កល់នៅក្រសួងពាណិជ្ជកម្ម ជាមុន។
- អ្នកទទួលសិទ្ធិផ្តាច់មុខ ស្របតាមមាត្រា ៣ នៃច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ អាចដាក់ពាក្យស្នើសុំកត់ត្រា និងតម្កល់លិខិតប្រគល់សិទ្ធិផ្តាច់មុខនៅនាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម ក្នុងរយៈពេល ៣(បី)ខែ យ៉ាងយូរ គិតចាប់ពីកាលបរិច្ឆេទចូលជាធរមាននៃលិខិតប្រគល់សិទ្ធិពីម្ចាស់ម៉ាក។
- ក្នុងករណីម្ចាស់ម៉ាក ឬអ្នកទទួលសិទ្ធិស្របច្បាប់ចង់ទទួលបាននូវការការពារសិទ្ធិផ្តាច់មុខលើការនាំចូល និងចែកចាយនូវគ្រប់ម៉ូដែល ឬផលបត្រម៉ាក (Trademark Portfolio) ដែលជ្រកក្រោមម៉ាកតែមួយ ត្រូវស្នើសុំកត់ត្រា និងតម្កល់លិខិតប្រគល់សិទ្ធិផ្តាច់មុខនៅក្រសួងពាណិជ្ជកម្ម នូវគ្រប់ម៉ូដែលទាំងអស់ ឬផលបត្រម៉ាក (Trademark Portfolio) ដែលជ្រកក្រោមម៉ាកនោះ។

បន្ទាប់ពីបានពិនិត្យលើលិខិតរបស់ **លោកប្រធាន** និងលទ្ធផលនៃកិច្ចប្រជុំជាបន្តបន្ទាប់កន្លងមក ក្រសួងពាណិជ្ជកម្ម សូមសម្រេចកំណត់នូវលក្ខណៈសម្បត្តិនៃយានយន្តថ្មី ដូចខាងក្រោម៖

១- មិនត្រូវបានចុះបញ្ជី ឬផ្ទេរកម្មសិទ្ធិយានយន្ត ដោយអាជ្ញាធរមានសមត្ថកិច្ចនៅប្រទេសណាមួយនៅឡើយ ឬ



២- មិនត្រូវបានលក់ ឬជួល លើកដំបូងបង្អស់ ពីក្រុមហ៊ុនផលិតយានយន្ត ក្រុមហ៊ុននាំចូលយានយន្ត ក្រុមហ៊ុនចែកចាយ ឬលក់យានយន្ត ឬភ្នាក់ងាររបស់ក្រុមហ៊ុនទាំងអស់នេះ ទៅឱ្យអ្នកប្រើប្រាស់ ឬ

៣- ត្រូវមានម៉ូដែលក្នុងឆ្នាំបច្ចុប្បន្នភាពនៃឆ្នាំម៉ូដែលរថយន្ត ឬម៉ូដែលមុន ឬក្រោយឆ្នាំបច្ចុប្បន្នភាពមួយឆ្នាំ ឬ

៤- ត្រូវមានឆ្នាំផលិតក្នុងឆ្នាំបច្ចុប្បន្ន ឬផលិតមុន ឬក្រោយឆ្នាំបច្ចុប្បន្នមួយឆ្នាំ (ឧទាហរណ៍នៃចំណុច ៣ និងចំណុច ៤ ក្នុងករណីយានយន្តមានម៉ូដែល ឬផលិតនៅឆ្នាំ២០២០ ត្រូវគិតចាប់ពីឆ្នាំ២០១៩ ដល់ឆ្នាំ ២០២១)។

ទន្ទឹមនេះ ខ្ញុំសូមជម្រាបជូន **លោកប្រធាន** ថា ក្រសួងពាណិជ្ជកម្មនឹងបន្តពន្យល់ និងដោះស្រាយក្តីកង្វល់របស់ភាគីទាំងពីរតាមគោលការណ៍ច្បាប់ និងបទប្បញ្ញត្តិនានាជាធរមានរបស់ព្រះរាជាណាចក្រកម្ពុជា នៅពេលក្រោយជាបន្តបន្ទាប់ទៀត។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **លោកប្រធាន** ជ្រាប និងអនុវត្តតាមការគួរ។

សូម **លោកប្រធាន** ទទួលនូវការរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ។

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ប៉ាន_សូរស័ក្តិ**

**ចម្លងជូន៖**
- ខុទ្ទកាល័យ**សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី**
- ខុទ្ទកាល័យឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ឯកសារ កាលប្បវត្តិ

សហព័ន្ធឧស្សាហកម្មយានយន្តកម្ពុជា
CAMBODIA AUTOMOTIVE INDUSTRY FEDERATION
ស.ឧ.យ.ក CAIF

# បញ្ហាប្រឈមក្នុងឧស្សាហកម្មយានយន្ត

## សិទ្ធិផ្តាច់មុខ

**រថយន្តជជុះ**

ស្ថិតក្រោមសិទ្ធិផ្តាច់មុខ



# បញ្ហាប្រឈមក្នុងឧស្សាហកម្មយានយន្ត

## ការប្រកួតប្រជែងលើទីផ្សារ

**ម៉ូដែលរថយន្ត៖**
ក្រុមហ៊ុនដែលទទួលបានសិទ្ធិចែកចាយ អាចនាំចូលតែម៉ូដែលរថយន្តដែលមាននៅក្នុងកិច្ចព្រមព្រៀងចែកចាយតែប៉ុណ្ណោះ ដោយឡែកអ្នកនាំចូលរថយន្តដែលមិនទទួលបានសិទ្ធិ អាចនាំចូលរថយន្តគ្រប់ម៉ាក និងម៉ូដែល ដោយពុំមានការរឹតត្បិត

**ការប្រកួតប្រជែងតំលៃ៖**
រថយន្តដែលនាំចូលដោយអ្នកនាំចូលរថយន្តដែលមិនទទួលបានសិទ្ធិចែកចាយមានតំលៃទាបជាង ដោយការបង់ពន្ធធ្វើឡើងតាមតារាងតំលៃពន្ធ ដោយឡែកក្រុមហ៊ុនដែលទទួលបានសិទ្ធិចែកចាយ បង់ពន្ធតាមតំលៃក្នុងវិក័យបត្រពីរោងចក្រ

**ចំណាយលើការវិនិយោគ៖**
ក្រុមហ៊ុនដែលទទួលបានសិទ្ធិចែកចាយ វិនិយោគលើអចលនទ្រព្យ អគារតាំងលក់រថយន្ត ផ្នែកសេវាកម្ម បុគ្គលិក ការធ្វើទីផ្សារ ។ល។ ធ្វើអោយតំលៃរថយន្តកើនឡើងខ្ពស់ បើធៀបជាមួយតំលៃរថយន្តដែលនាំចូលដោយអ្នកដែលមិនទទួលបានសិទ្ធិចែកចាយ ដោយគ្រាន់តែកម្មង់ និងទិញរថយន្តពីក្រៅប្រទេសយកមកលក់ផ្ទាល់

សហព័ន្ធឧស្សាហកម្មយានយន្តកម្ពុជា
CAMBODIA AUTOMOTIVE INDUSTRY FEDERATION
ស.ឧ.យ.ក
CAIF

# បញ្ហាប្រឈមក្នុងឧស្សាហកម្មយានយន្ត

## ការប្រកួតប្រជែងលើទីផ្សារ



មជ្ឈមណ្ឌលលក់



សំភារៈបរិក្ខា



ផ្នែកសេវាកម្ម



សកម្មភាពជួយសង្គម



ការងារ និងបណ្តុះបណ្តាល

**ចំណាយវិនិយោគ**

HGB® GROUP

# បញ្ហាប្រឈមក្នុងឧស្សាហកម្មយានយន្ត

## បទបញ្ញត្តិបច្ចេកទេសយានយន្ត

- All ASEAN Government already signed ASEAN MRA, last countries is Myanmar has signed the Agreement on 16th January 2021
- For Phase-1 there are 19UNRs for ASEAN MRA will be implemented
- By Implementing ASEAN MRA on 2022, Technical Barriers must be eliminated

### 1. ASEAN Mutual Recognition Arrangement (MRA) On Type Approval For Automotive Products




### 2. 19 UNRs for ASEAN MRA

| NO. | AUTOMOTIVE PRODUCT | UN REGULATION | FOUR WHEELERS | TWO WHEELERS |
|---|---|---|---|---|
| 1 | Braking System | R13 | O | |
| 2 | Braking System | R13H | O | |
| 3 | Safety-belt anchorage | R14 | O | |
| 4 | Safety-belt and Restraint System | R16 | O | |
| 5 | Seats | R17 | O | |
| 6 | Head Restraints | R25 | O | |
| 7 | Audible Warning Device | R28 | O | |
| 8 | Pneumatic Tyre | R30 | O | |
| 9 | Speedometer | R39 | O | |
| 10 | Exhaust Emission | R40 | | O |
| 11 | Noise | R41 | | O |
| 12 | Safety Glazing Materials and their Installation | R43 | O | |
| 13 | Devices for Indirect Vision | R46 | O | |
| 14 | Exhaust Emission | R49 | O | |
| 15 | Sound Emission | R51 | O | |
| 16 | Pneumatic Tyre | R54 | O | |
| 17 | Pneumatic Tyre | R75 | | O |
| 18 | Steering Equipment | R79 | O | |
| 19 | Exhaust Emission | R83 | O | |

### 3. Progress of Signing Agreement



# បញ្ហាប្រឈមក្នុងឧស្សាហកម្មយានយន្ត

## បទបញ្ញត្តិបច្ចេកទេសយានយន្ត

### Execution Plan of UNRs Adoption

The Implementation timeline : 2 Stages
Stage-1 : Implementation based on test report/certificate acceptance.
Stage-2 : Full harmonization as per framework stipulated under WP29 (1958 Agreement)

**Stage-1 : 2021 – 2025**
**Stage-2 : 2025 onwards**

**10 UNRs**

R13 : Braking System
R13H : Braking System (Passenger Car)
R17 : Seat
R25 : Head Restraint
R28 : Audible Warning Device
R39 : Speedometer
R41 : Noise for motorcycle
R46 : Rear View Mirror
R51 : Noise Emission
R79 : Steering System

**Stage-1 : 2022 – 2027**
**Stage-2 : 2027 onwards**

**6 UNRs**

R 14 : Anchorage of seat belt
R 16 : Seat Belt
R 30 : Pneumatic tyre (passenger vehicle)
R 43 : Safety Glazing Material
R 54 : Pneumatic tyre (commercial vehicle)
R75 : Pneumatic tyre (motorcycle)

**Stage-1 : 2023 – 2027 (Euro 4)**
**Stage-2 : 2027 onwards (Euro 5)**

**3 UNRs**

R 40 : Exhaust emission for motorcycle
R 49 : Exhaust emission with reference mass > 2610 kg
R 83 : Exhaust emission with reference mass ≤ 2610 kg

# បញ្ហាប្រឈមក្នុងឧស្សាហកម្មយានយន្ត

## បទបញ្ញត្តិបច្ចេកទេសយានយន្ត

*រាជរដ្ឋាភិបាល បានអនុម័តសំរាប់ការអនុវត្តបទបញ្ញត្តិបច្ចេកទេស (Standard) លើផលិតផលយានយន្តថ្មី ចាប់ពីថ្ងៃទី ១ ខែមករា ឆ្នាំ ២០២០ មកម្ល៉េះ ដោយឡែករថយន្តជជុះ មិនតម្រូវអោយអនុវត្តន៍នោះទេ។*

| ល.រ | ឆ្នាំ អនុវត្ត | លេខ ស្តង់ដារកម្ពុជា | UNR | ចំណងជើងស្តង់ដារ | ចំណាត់ថ្នាក់ |
|---|---|---|---|---|---|
| 1 | 2020 | CS 530:2016 | R39 | កុងទ័រល្បឿន | L |
| 2 | 2020 | CS 532:2016 | R41 | សំលេងសម្រាប់ម៉ូតូ | L |
| 3 | 2020 | CS 538:2016 | R60 | ផ្ទាំងត្រួតពិនិត្យការបើកបរ | L |
| 4 | 2020 | CS 539:2016 | R75 | សំបកកង់សម្រាប់ម៉ូតូ | L |
| 5 | 2020 | CS 537:2016 | R54 | សំបកកង់រថយន្ត-ដឹកទំនិញ | N1 |
| 6 | 2020 | CS 529:2016 | R30 | សំបកកង់រថយន្ត-រថយន្តទេសចរណ៍ | M1 |
| 7 | 2020 | CS 533:2016 | R43 | កញ្ចក់សុវត្ថិភាព | M1 & N1 |
| 8 | 2021 | CS 549:2019 | R28 | បរិក្ខារព្រមានដោយសញ្ញាជាសំឡេង សម្រាប់យានយន្ត Audible Warning Device | L |
| 9 | 2021 | CS 530:2016 | R39 | កុងទ័រល្បឿន | M1 & N1 |
| 10 | 2021 | CS 534:2016 | R46 | កញ្ចក់មើលក្រោយ | M1 & N1 |
| 11 | 2022 | CS 525:2016 | R14 | បង្គោលខ្សែក្រវ៉ាត់សុវត្ថិភាព | M1 & N1 |
| 12 | 2022 | CS 526:2016 | R16 | ខ្សែក្រវ៉ាត់សុវត្ថិភាព | M1 & N1 |
| 13 | 2022 | CS 535:2016 | R49 | ការបំភាយផ្សែងម៉ាស៊ីត (ចាប់ពី EURO IV ឡើងទៅ) | M1 & N1 |
| 14 | 2022 | CS 541:2016 | R83 | ការបំភាយផ្សែងសម្រាប់រថយន្តធុនស្រាល (ចាប់ពី EURO IV ឡើងទៅ) | M1 & N1 |
| 15 | 2023 | CS 531:2016 | R40 | ការបំភាយផ្សែងសម្រាប់ម៉ូតូ (EURO III) | L |
| 16 | 2023 | CS 540:2016 | R79 | ឧបករណ៍ដៃចង្កូត | M1 & N1 |
| 17 | 2023 | CS 523:2016 | R13 | ប្រព័ន្ធហ្វ្រាំង | N1 |
| 18 | 2023 | CS 524:2016 | R13H | ប្រព័ន្ធហ្វ្រាំងសម្រាប់រថយន្តទេសចរណ៍ | M1 & N1 |
| 19 | 2024 | CS 527:2016 | R17 | កៅអី | M1 & N1 |
| 20 | 2024 | CS 528:2016 | R25 | ក្បាលកៅអី | M1 & N1 |
| 21 | 2024 | CS 549:2019 | R28 | បរិក្ខារព្រមានដោយសញ្ញាជាសំឡេង សម្រាប់យានយន្ត Audible Warning Device | M1 & N1 |
| 22 | 2024 | CS 536:2016 | R51 | ការបន្លឺសំឡេង | M1 & N1 |

# បញ្ហាប្រឈមក្នុងឧស្សាហកម្មយានយន្ត

## បទបញ្ញត្តិបច្ចេកទេសយានយន្ត

*រថយន្តថ្មី ដែលនាំចូលចែកចាយដោយក្រុមហ៊ុនទទួលបានសិទ្ធិៈ*

- អនុលោមតាមបទដ្ឋានបច្ចេកទេសពីវិទ្យាស្ថានស្តង់ដារកម្ពុជា
- ទទួលបានការធានាគុណភាពពី ៣ ទៅ ៥ ឆ្នាំ
- សេវាកម្មលក្ខណៈស្តង់ដារ និងគ្រឿងបន្លាស់សុទ្ធពីរោងចក្រ
- ទទួលបានសេវាថែទាំយានយន្តជាប្រចាំ និងអត្ថប្រយោជន៍ផ្សេងៗទៀត








លិខិតអនុម័តបទដ្ឋានបច្ចេកទេស




សញ្ញាសុវត្ថិភាព "S"

*រថយន្តថ្មី ដែលនាំចូលចែកចាយដោយក្រុមហ៊ុនដែលមិនទទួលបានសិទ្ធិៈ*

- មិនមានការធានាគុណភាព និង សុវត្ថិភាពរថយន្ត
- មិនអនុលោមតាមបទដ្ឋានបច្ចេកទេស
- មិនមានប្រវត្តិច្បាស់លាស់ក្នុងការប្រើប្រាស់
- មិនមានសេវាកម្ម និងសេវាថែទាំយានយន្តតាមស្តង់ដារ
- បញ្ហាផ្សេងៗអាចកើតមានក្នុងកំឡុងពេលប្រើប្រាស់

# បញ្ហាប្រឈមក្នុងឧស្សាហកម្មយានយន្ត

## ការនាំចូលរថយន្តជជុះ

*ប្រទេសភាគច្រើន ក្នុងតំបន់អាស៊ានបានរឹតត្បិតដល់ការនាំចូលរថយន្តជជុះ ដោយឡែកប្រទេសកម្ពុជានៅបន្តអនុញ្ញាតិអោយនាំចូលរថយន្តជជុះ ដោយពុំមានការរឹតត្បិត ឬ មានបទបញ្ញត្តិបច្ចេកទេសដើម្បីធានាសុវត្ថិភាពយានយន្តនោះឡើយ។*

| ប្រទេស | ដៃចង្កូត | បទបញ្ញត្តិនៃការនាំចូលរថយន្តជជុះ | មតិបន្ថែម |
|---|---|---|---|
| ឥណ្ឌូនេស៊ី | ស្តាំ | មិនអនុញ្ញាតិអោយនាំចូលទាំងស្រុង | មិនមាន |
| ឡាវ | ឆ្វេង | មិនអនុញ្ញាតិអោយនាំចូលទាំងស្រុង | មិនមាន |
| ថៃ | ស្តាំ | មិនអនុញ្ញាតិអោយនាំចូល តែមានករណីលើកលែង | អនុញ្ញាតិសំរាប់រដ្ឋាភិបាល នាំចូលបណ្តោះអាសន្ន ឬប្រើប្រាស់ផ្ទាល់ខ្លួន |
| ហ្វីលីពីន | ឆ្វេង | មិនអនុញ្ញាតិអោយនាំចូល តែមានករណីលើកលែង | អនុញ្ញាតិសំរាប់ប្រើប្រាស់ផ្ទាល់ខ្លួន |
| វៀតណាម | ឆ្វេង | អនុញ្ញាតិអោយនាំចូល តែត្រូវបង់ពន្ធបន្ថែមពី ៥ពាន់ ទៅ ១៥ពាន់ដុល្លារ | រថយន្តជជុះថ្លៃជាងរថយន្តថ្មី និងមិនអាចលក់ ឬចែកចាយរថយន្តជជុះបាន |
| ម៉ាឡេស៊ី | ស្តាំ | អនុញ្ញាតិអោយនាំចូលរថយន្តជជុះមានអាយុកាលត្រឹម ៥ ឆ្នាំ ក្រោយឆ្នាំបច្ចុប្បន្ន | តំរូវអោយមានអាជ្ញាប័ណ្ណនាំចូល និងហាមធ្វើជំនួញចាប់ពីឆ្នាំ ២០១៦ |
| សិង្ហបុរី | ស្តាំ | អនុញ្ញាតិអោយនាំចូលរថយន្តជជុះមានអាយុកាលត្រឹម ៣ ឆ្នាំ ក្រោយឆ្នាំបច្ចុប្បន្ន | តំរូវអោយពិនិត្យលក្ខណៈបច្ចេកទេសមុនអនុញ្ញាតិអោយនាំចូល |
| ព្រុយនេ | ស្តាំ | អាយុកាលរថយន្តត្រូវកំណត់ដោយក្រុមហ៊ុនទទួលបានសិទ្ធិចែកចាយ | សំរាប់ក្រុមហ៊ុន មិនត្រូវលើសពីអាយុយានយន្ត ៣ ឆ្នាំ<br>សំរាប់ប្រើប្រាស់ផ្ទាល់ខ្លួន មិនត្រូវលើសពីអាយុយានយន្ត ៥ ឆ្នាំ |
| មីយ៉ាន់ម៉ា | ឆ្វេង | អនុញ្ញាតិអោយនាំចូលរថយន្តជជុះមានអាយុកាលត្រឹម ៥ ឆ្នាំ ក្រោយឆ្នាំបច្ចុប្បន្ន | តំរូវអោយមានអាជ្ញាប័ណ្ណនាំចូល |

# បញ្ហាប្រឈមក្នុងឧស្សាហកម្មយានយន្ត

## រថយន្តអគ្គិសនី



# បញ្ហាប្រឈមក្នុងឧស្សាហកម្មយានយន្ត

## រថយន្តអគ្គិសនី

- រថយន្តអគ្គិសនី កំពុងចរាចរណ៍លើទីផ្សារក្នុងប្រទេសកម្ពុជា ស្ថិតក្នុងចំនួនតិចនៅឡើយក្នុងឆ្នាំ ២០២១ នេះ។
- ក្រុមហ៊ុនធំៗមួយចំនួន បានកំពុងចែកចាយរថយន្តអគ្គិសនីលើទីផ្សារអន្តរជាតិ និងគ្រោងនាំចូលមកប្រទេសកម្ពុជា ចាប់ពីឆ្នាំ ២០២២ នេះតទៅ និងផ្លាស់ប្តូរទាំងស្រុងទៅរថយន្តអគ្គិសនីក្នុងពេលដ៏ខ្លីខាងមុខ។
- ហេតុដូចនេះ រាជរដ្ឋាភិបាលគួរចាប់ផ្តើមរៀបចំគោលនយោបាយ បទដ្ឋានយានយន្ត ឧបករណ៍ និងទីតាំងសាកភ្លើង ដើម្បីបង្កភាពងាយស្រួលក្នុងការនាំចូល និងចែកចាយរថយន្តនាពេលឆាប់ៗនេះ។

2040



MG ZS



JAGUAR I-PACE

2030

EV

2020



LETIN MENGO



LEVDEO

- រាជរដ្ឋាភិបាល បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងកាត់បន្ថយឧស្ម័នបំភាយពីយានយន្តត្រឹមឆ្នាំ ២០៤០។



សូមអរគុណ